ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៧អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលក្បាច់ចុងកអាវ និងក្បាច់កដៃអាវ ឯកសណ្ឋានធំលេខ ១ ( កុជស ) របស់នគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/០៨៣ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០១ ស្តីពីរូបភាពលំដាប់ស័ក្តិរបស់កងកម្លាំងនគរបាលជាតិ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០០ ស្តីពីការកែសំរួលឯកសណ្ឋាន និងផ្លាកសញ្ញារបស់នគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ត្រូវបានរៀបចំកែសំរួលជាថ្មី នូវក្បាច់ចុងកអាវ និងក្បាច់កដៃអាវឯកសណ្ឋានធំលេខ ១ ( អាវកុជស ) របស់នគរបាលជាតិកម្ពុជា ដូចខាងក្រោម :

ក- ក្បាច់ចុងកអាវ : ចុងកអាវទាំងសងខាងមានក្បាច់កំរងក្បូរស្រូវពណ៌មាស ផ្ទៃពណ៌មាសដែលមានទំហំ : បណ្តោយប្រវែង ៧០ ម.ម ទទឹងខាងដើមប្រវែង ៣០ ម.ម និងទទឹងខាងចុងប្រវែង ៤០ ម.ម ។

ខ- ក្បាច់កដៃអាវ : ពីចុងដៃអាវទាំងសងខាងឡើងមកលើប្រវែង ៨០ ម.ម មានចំណែកដែលមានទំហំទទឹងប្រវែង ១៥ ម.ម :

- សំរាប់ថ្នាក់ឧត្តមសេនីយ៍មានចំនួនក្បាច់ផ្កាផ្គូងពណ៌មាស
- សំរាប់ថ្នាក់វរសេនីយ៍មានចំនួនក្រណាត់លោតពណ៌មាស ។

**មាត្រា ២** : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កក្កដា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ